ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៤/១៩ - ខេន ស្ព័ត ស៊ូ

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាំង អេងថុង**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ខួន ស៊ីផាន់**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៧៨ ៧៧៧ ៦១៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក សុះ មើ ប្រធានរដ្ឋបាល

២- លោក អ៊ុក អ៊ុន បុគ្គលិករដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៨១ ៨៨៧ ៧០១/០៨១ ៤៧៨ ០១៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោកស្រី ម៉ន ចន្ទា មន្ត្រីសហព័ន្ធសហជីពកម្ពុជា

២- លោកស្រី រិន សេរី ប្រធានសហជីពកម្ពុជា(មូលដ្ឋាន)

៣- លោកស្រី ហែន បុប្ផា ហិរញ្ញិកសហជីពកម្ពុជា(មូលដ្ឋាន)

៤- លោកស្រី សាន់ អាំមីន កម្មការិនី

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែស្នើសុំក្រុមហ៊ុន រាល់ការកាត់ភាគទានកម្មករ សូមដាក់ឈ្មោះសហជីពឱ្យបានច្បាស់លាស់នៅលើក្រដាសបើកលុយ។ ដោយឡែក ក្រុមហ៊ុនបានបញ្ជាក់ថា សហជីពមានរហូតដល់ប្រាំបីសហជីព ហើយព័ត៌មានដែលក្រុមហ៊ុនមានគ្រប់គ្រាន់ ហើយកម្មករចង់ដឹងថា ចូលសហជីពមួយណា គាត់អាចមកសួរនៅរដ្ឋបាលបាន។

២- កម្មករនិយោជិតនៅតែទាមទារស្នើសុំ ឱ្យទូទាត់លុយឈ្មោះ វង់ ថារី ដែលក្រុមហ៊ុនបានកាត់លុយចំនួនប្រាំពីរថ្ងៃ (នៅពេលគាត់ដាក់ច្បាប់ពិសេស។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្កូត ស៊ូ លេខ ១០២៥ ក.ប/កធ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា កណ្តាល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្កូត ស៊ូ ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារចំនួន៧ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារ និងធ្វើការផ្សះផ្សា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៥ ចំណុច លើការទាមទារចំនួន៧ចំណុច។ ចំណុចមិនសះជា ចំនួន ២ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ តាមរយៈ

THE ARBITRATION COUNCIL

របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១០២៥ កប/កធ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការអញ្ជើញភាគីនិយោជក និងភាគីកម្មករ និយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុច នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទទាំង ២ នេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- ប័ណ្ណប៉ាតង់ឆ្នាំ២០១៩ ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ PTL 201902159 អពដ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩។

២- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ៦៨២៣ ឧសកឧវប១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៣- ប្រកាសបង្កើតរោងចក្រ ខេន ស្ព័ត ស៊ូ លេខ ៦២៥ ឧសកឧប្រក១២ ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៤- លិខិតផ្ទេរសិទ្ធិរបស់លោក ស្តេឡា ចាង ជានាយកប្រតិបត្តិក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ផ្ទេរសិទ្ធិជូនលោក សុះ មើ លោក ឡាច សារុន និងលោក អ៊ុក អ៊ុន ចុះថ្ងៃសៅរ៍ ២កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះទិដ្ឋាការលេខ ៥១១ ក.ប/ក.ធ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ដោយមន្ទីរការងារខេត្តកំពង់ឆ្នាំង។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៩។

៧- លិខិតលេខ ០៣១/១៩ ខសស ចុះថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការប្តឹងជំទាស់លិខិតគ្មានលេខរបស់តំណាងសហព័ន្ធសហជីពកម្ពុជា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។

៨- ទម្រង់បែបបទកាត់ភាគទានកម្មករជូនសហជីពយុវជនខ្មែរ។

៩- ពាក្យសុំចូលជាសមាជិកសហជីព។

១០-លិខិតបញ្ជាក់ការយល់ព្រមឱ្យកាត់ប្រាក់ភាគទានសមាជិកសហជីពកម្ពុជា របស់ឈ្មោះ នួន ស្រីមុំ និង ណាង វណ្ណី ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩។

១១- លិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលប្រចាំខែរបស់សហជីពសេរីកម្មករនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ។

១២- លិខិតបញ្ជាក់ការយល់ព្រមឱ្យកាត់ប្រាក់ភាគទានសមាជិកសហជីពកម្ពុជា របស់ឈ្មោះ ជុំ ជ្រែង ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតបញ្ចូលភស្តុតាង ចុះថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៩ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលរួមមាន៖
-ឈ្មោះកម្មករនិយោជិតលាឈប់ពីសហជីព ហើយក្រុមហ៊ុននៅតែកាត់ប្រាក់ភាគទានទៀត
-ឈ្មោះអ្នកចូលសមាជិកសហជីពក្រុមហ៊ុនកាត់លើស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១០២៥ ក.ប/កធ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០០៧/១៩ ក.ប/ក.ធ.ល.ប.វ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៧០ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៧១ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន ខេន ស្គ័ត ស៊ូ គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផលិតស្បែកជើង។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៩៨១២ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្គ័ត ស៊ូ)*។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ប្រាក់ភាគទាន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត**

- ភាគីទាំងពីរបានទទួលស្គាល់ថា៖
  - ០ ជាការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបានបញ្ជាក់នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត អំពីចំនួនប្រាក់ឈ្នួលដែលត្រូវបានកាត់សម្រាប់បង់ប្រាក់ភាគទានឱ្យសហជីព។
  - ០ រៀងរាល់ខែ មុនពេលកាត់ប្រាក់ភាគទាន និយោជកតែងតែចម្លងនូវតារាងរាយនាមសមាជិកសហជីព ជូនប្រធានសហជីព ដើម្បីឱ្យពួកគាត់ពិនិត្យនិងចុះហត្ថលេខា។
  - ០ ក្នុងករណីកម្មករនិយោជិតពិនិត្យឃើញថា និយោជកកាត់ប្រាក់ភាគទានលើសចំនួន ឬមានភាពមិនប្រក្រតី កម្មករនិយោជិតអាចទៅពិនិត្យឡើងវិញជាមួយជំនួយការនៅក្នុងអគារបាន។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ០ មានកម្មករនិយោជិតខ្លះបានលាឈប់ពីសហជីពហើយ ប៉ុន្តែរំលងបាន២-៣ខែ បន្ទាប់ពីបានលាឈប់ និយោជកនៅតែបន្តកាត់ប្រាក់ឈ្នួលរបស់គាត់សម្រាប់បង់ភាគទានសហជីព។
  - ០ កម្មករនិយោជិតចូលជាសមាជិកតែមួយសហជីពប៉ុណ្ណោះ ប៉ុន្តែ ត្រូវនិយោជកកាត់ប្រាក់ភាគទាន ២ ទៅ ៣ សហជីព ដូចជាកម្មករនិយោជិត សាន់ អាំមីន ត្រូវបាននិយោជកកាត់ប្រាក់ឈ្នួលបង់ភាគទាន ២ សហជីព និងកម្មករនិយោជិត ពេជ្រ ផានី ត្រូវបាននិយោជកកាត់ប្រាក់ឈ្នួលបង់ភាគទាន ៣ សហជីព។ កម្មករនិយោជិតទាំង ២ នាក់នេះ បានទៅសាកសួរបញ្ជាក់ជាមួយនិយោជក និយោជកបានឈប់កាត់មួយរយៈ ប៉ុន្តែ ក្រោយមកនិយោជកនៅតែបន្តកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីពមិនត្រឹមត្រូវបែបនេះ។
  - ០ កម្មករនិយោជិតជួបផលវិបាកក្នុងការទៅពិនិត្យឡើងវិញ ជាមួយជំនួយការនៃអគារនីមួយៗទាក់ទងនឹងការកាត់ប្រាក់ភាគទានខុស ដោយហេតុថា ជាប់រវល់ធ្វើការងារ និងខ្លាចប្រធានក្រុមស្តីបន្ទោស ហើយប្រធានចិនធ្លាប់ស្តីបន្ទោសឱ្យកម្មករនិយោជិតថា រញ៉េរញ៉ៃ និងមិនឱ្យធ្វើការបន្ថែមម៉ោង។
- ភាគីនិយោជកបានលើកឡើងថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖

- ០ និយោជកកាត់ប្រាក់ឈ្នួលបង់ចូលប្រាក់ភាគទានសហជីពស្របតាមលិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ប្រាក់ភាគទានសហជីព និងហត្ថលេខា ស្នាមម្រាមដៃរបស់កម្មករនិយោជិត។
- ០ បច្ចុប្បន្ន និយោជកបានបញ្ជាក់លើបង្កាន់ដៃបើកប្រាក់ឈ្នួលយ៉ាងច្បាស់ថា "ប្រាក់ភាគទានសហជីព" និងបានបញ្ជាក់ពីចំនួនប្រាក់ឈ្នួលដែលត្រូវបានកាត់បង់ប្រាក់ភាគទានសហជីពដែលអាចឱ្យកម្មករនិយោជិតអាចយល់ច្បាស់ហើយ។
- ០ បើសិនជាមានបញ្ហាទាក់ទងនឹងការកាត់ប្រាក់ភាគទានសហជីព និយោជកបើកសិទ្ធិឱ្យកម្មករនិយោជិតទៅពិនិត្យឡើងវិញជាមួយជំនួយការក្នុងអគារនីមួយៗបាន។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត វង់ ថារី នៅពេលដែលគាត់ឈប់សម្រាកពិសេស**

- ភាគីទាំងពីរបានទទួលស្គាល់ថា ៖
  - ០ ជាការអនុវត្តនៅក្នុងក្រុមហ៊ុន ក្នុងករណីកម្មករនិយោជិតមិនអាចមកបំពេញលិខិតសុំច្បាប់ឈប់សម្រាកនៅថ្ងៃដែលពួកគាត់ប្រើប្រាស់ការឈប់សម្រាកពិសេស កម្មករនិយោជិតអាចបំពេញលិខិតសុំច្បាប់ ក្នុងអំឡុងពេល ៣ថ្ងៃ នៅពេលដែលមកធ្វើការវិញ។
  - ០ កម្មករនិយោជិត វង់ ថារី បានឈប់សម្រាកចំនួន ៧ថ្ងៃ ដោយមូលហេតុកូនមានជំងឺ។ គាត់មិនបានមកបំពេញលិខិតសុំច្បាប់ឈប់សម្រាកពិសេសទេ ក្នុងអំឡុងពេល ៣ថ្ងៃ ដែលគាត់បានមកបំពេញការងារវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ស្វាមីរបស់កម្មករនិយោជិត វង់ ថារី ឈ្មោះ សៀង នីម បានបំពេញលិខិតសុំច្បាប់ឈប់សម្រាកពិសេសជំនួសគាត់ និងបានផ្ញើទៅប្រធានក្រុម នៅពេលដែលគាត់កំពុងតែឈប់សម្រាកនេះ។ យ៉ាងណាមិញ បន្ទាប់ពីបានលើកឡើងដូចខាងលើនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា គាត់មិនដឹងអំពីអង្គហេតុដែលបានកើតឡើងច្បាស់លាស់នោះទេ ដោយហេតុថា នៅថ្ងៃសវនាការ ពុំមានវត្តមានរបស់កម្មករនិយោជិត វង់ ថារី។
- ភាគីនិយោជកបានលើកឡើងថា និយោជកបានទទួលតែសំបុត្រពេទ្យទេ ដែលយកទៅឱ្យក្រុមហ៊ុនប្រមាណ ២០ថ្ងៃ បន្ទាប់ពីចូលធ្វើការវិញ ពុំបានទទួលលិខិតសុំការអនុញ្ញាតឈប់សម្រាកពិសេសនោះទេ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដើម្បីបង់ប្រាក់ភាគទាន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដើម្បីបង់ប្រាក់ភាគទាន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែរ ឬទេ?

មាត្រា ៦១ នៃច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ចែងថា ៖ *និយោជកត្រូវរក្សាទុកកំណត់ត្រាទាំងឡាយនៅពេលណាដែលខ្លួនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដើម្បីបង់ភាគទានសហជីព ឬប្រាក់សេវាភ្នាក់ងារ។*

*កំណត់ត្រាទាំងនេះ ត្រូវដាក់បញ្ចូលនូវកាលបរិច្ឆេទដែលការកាត់នេះត្រូវបានអនុញ្ញាតឱ្យធ្វើឡើងដោយកម្មករនិយោជិតពាក់ព័ន្ធ កាលបរិច្ឆេទនិងចំនួនប្រាក់ភាគទានដែលបានកាត់សម្រាប់កម្មករនិយោជិតម្នាក់ៗ និងកាលបរិច្ឆេទ និងចំនួនទឹកប្រាក់ដែលបានផ្ទេរទៅឱ្យសហជីពពាក់ព័ន្ធ។" ។*

យោងតាមមាត្រា ៦១ នៃច្បាប់ស្តីពីសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចរក្សាទុកកំណត់ត្រាទាំងអស់ នៅពេលដែលបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដើម្បីបង់ប្រាក់ភាគទានជូនសហជីព។ កំណត់ត្រានេះ ត្រូវរួមបញ្ចូលនូវកាលបរិច្ឆេទនៃការអនុញ្ញាតដោយកម្មករនិយោជិតពាក់ព័ន្ធ កាលបរិច្ឆេទនិងចំនួនប្រាក់ភាគទានដែលត្រូវបានកាត់សម្រាប់កម្មករនិយោជិតម្នាក់ៗ និងចំនួនទឹកប្រាក់ដែលត្រូវបានផ្ទេរទៅឱ្យសហជីពពាក់ព័ន្ធ។

តាមរយៈអង្គហេតុ ភាគីនិយោជកបានរក្សាទុកនូវកំណត់ត្រានេះទាំងអស់ នៅរៀងរាល់ពេលដែលខ្លួនបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដើម្បីបង់ប្រាក់ភាគទានជូនសហជីពរួចហើយ។ លើសពីនេះ ភាគីនិយោជកបានអនុញ្ញាតឱ្យភាគីកម្មករនិយោជិតមកពិនិត្យកំណត់ត្រានេះ ជាមួយជំនួយការនៃអគារនៅក្នុងក្រុមហ៊ុនទៀត ក្នុងករណីដែលភាគីកម្មករនិយោជិតមានមន្ទិលសង្ស័យថា និយោជកកាត់ប្រាក់ភាគទានលើសចំនួន ឬមានភាពមិនប្រក្រតី។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនស្របតាមស្មារតីនៃមាត្រា ៦១ នៃច្បាប់ស្តីពីសហជីពខាងលើរួចហើយ។

លើសពីនេះ ពាក់ព័ន្ធនឹងការទាមទារខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតខ្លះ ត្រូវបាននិយោជកកាត់ប្រាក់ឈ្នួលទៅបង់ប្រាក់ភាគទានជូនសហជីពដល់ទៅ ២ ឬ ៣ ហើយនៅពេលដែលកម្មករនិយោជិតតវ៉ា និយោជកក៏បានឈប់កាត់មួយរយៈ ប៉ុន្តែ ២-៣ខែ ក្រោយមក និយោជកបានបន្តកាត់ឡើងវិញ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើម្បីកុំឱ្យមានកំហុសនេះកើតឡើងដដែលៗ នៅពេលដែលកម្មករនិយោជិតលាឈប់ពីសហជីពណាមួយហើយ គាត់ត្រូវតែដាក់លិខិតលាឈប់សមាជិកភាពពីសហជីពទៅឱ្យនិយោជកបានដឹង ដើម្បីឱ្យរដ្ឋបាលទុកជាឯកសារ កុំឱ្យច្រឡំកាត់ឡើងវិញទៀត។ នៅពេលដែលកម្មករនិយោជិតប្រាប់ផ្ទាល់មាត់ និយោជកអាចភ្លេច ឬគ្មានសំអាងឈប់កាត់ ព្រោះនិយោជកមានកាតព្វកិច្ចត្រូវកាត់ប្រាក់ភាគទាននេះពេលមានសំណើឯកសារពីសហជីព។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព អនុសញ្ញារួម បទបញ្ជាផ្ទៃក្នុង កិច្ចសន្យាការងារ កិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ឬការអនុវត្តកន្លងមកណាមួយ ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ភាគទានជូន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកពុំមានកាតព្វកិច្ចក្នុងការសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ភាគទានជូន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសរសេរឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ភាគទានជូន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត វង់ ថារី នៅពេលដែលគាត់ឈប់សម្រាកពិសេស**

ក្នុងករណីនេះ ភាគីទាំងពីរពុំមានទំនាស់ទាក់ទងនឹងការប្រើប្រាស់សិទ្ធិឈប់សម្រាកពិសេសនោះទេ។

THE ARBITRATION COUNCIL

បញ្ហានៃទំនាស់របស់ភាគីទាំងពីរ គឺទាក់ទងនឹងនីតិវិធីនៃការសុំច្បាប់ឈប់សម្រាក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត វង់ ថារី សម្រាប់ការឈប់សម្រាករបស់គាត់ ដែរ ឬទេ?

ប្រការ ១.១០ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខេន ស្ពត ស៊ូ លេខ ៥១១ ក.ប/ក.ធ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ចែងថា ៖ *"... កម្មករនិយោជិតគ្រប់រូបត្រូវគោរព និងអនុវត្តតាមបែបបទស្នើសុំច្បាប់ដែលក្រុមហ៊ុនបានកំណត់។ រាល់ការសុំច្បាប់ និងការឈប់សម្រាកត្រូវបំពេញលិខិតសុំច្បាប់ និងបញ្ជូនទៅផ្នែកទូទាត់ប្រាក់បៀវត្សរ៍ និងវត្តមាន។ ក្នុងរយៈពេល ៣ថ្ងៃ ក្រោយពេលត្រឡប់មកពោងចក្រវិញ ទើបអាចបញ្ចប់បែបបទសុំច្បាប់។"*

យោងតាមប្រការ ១.១០ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ពត ស៊ូ ត្រូវដាក់លិខិតសុំច្បាប់ឈប់សម្រាកទៅនិយោជក ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីបានឈប់សម្រាក។

នៅក្នុងសំណុំរឿងលេខ ០៩១/១៥-ដាប់ប៊ីលយូ អ៊ែនដ៍ ឌី (កម្ពុជា) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"ភាពចាំបាច់ក្នុងការបំពេញបែបបទសុំច្បាប់ ដែលលើកឡើងដោយភាគីនិយោជក ព្រោះសំណុំបែបបទទាំងនេះជាឯកសារសំខាន់ ដែលក្រុមហ៊ុនត្រូវរក្សាទុកសម្រាប់ការគណនាប្រាក់ឈ្នួលរបស់កម្មករនិយោជិត ការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងារ ព្រមទាំងការពង្រឹងវិន័យ និងរបៀបរបបក្នុងការសុំច្បាប់នៅក្នុងក្រុមហ៊ុនផងដែរ..."*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា ស្វាមីរបស់កម្មករនិយោជិត វង់ ថារី ឈ្មោះ សៀង នីម បានបំពេញលិខិតសុំច្បាប់ឈប់សម្រាកពិសេសជំនួសគាត់ និងបានផ្ញើនៅប្រធានក្រុម នៅពេលដែលគាត់កំពុងតែឈប់សម្រាក ដោយពុំបានបង្ហាញភស្តុតាងថា បានយកលិខិតសុំច្បាប់ពិសេសទៅឱ្យដល់ដៃប្រធានក្រុម ឬរដ្ឋបាលទេ។ យ៉ាងណាមិញ ភាគីនិយោជកបានលើកឡើងថា និយោជកបានទទួលតែសំបុត្រពេទ្យទេ ប៉ុន្តែពុំបានទទួលលិខិតសុំច្បាប់ឈប់សម្រាកពិសេសនោះទេ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧៩/០៥-អេវើហ្គ្រីន, លេខ ១០១/០៨-ដីឌីអ៊ីម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទឹកថ្លា ផ្កាហ្វា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី ១៨, លេខ ១៤៨/១១-ដាយ យ៉ាំង និងលេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាងជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញ វ៉ែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុច[illegible], លេខ [illegible]/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ០៣២/១៦-អ៊ីជេនិធី ក្លូបិល ស្ព[illegible] (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រៅពីការអះអាងនៅក្នុងសវនាការ ភាគីកម្មករនិយោជិតមិនបានផ្តល់ភស្តុតាងជាក់លាក់ណាមួយ ដើម្បីគាំទ្រអំណះអំណាងដែលថា ស្វាមីរបស់កម្មករនិយោជិត វង់ ថាវី ពិតជាបានបំពេញលិខិតសុំច្បាប់ឈប់សម្រាកពិសេសជំនួសកម្មករនិយោជិត វង់ ថាវី និងបានផ្ញើនៅប្រធានក្រុមនោះទេ។

លើសពីនេះ ភាគីនិយោជកបានបញ្ជាក់ថា នៅពេលដែលកម្មករនិយោជិត វង់ ថាវី មកបំពេញការងារនៅក្រុមហ៊ុនវិញ គាត់ពុំបានទៅបំពេញបែបបទសុំច្បាប់ទេ គាត់បានប្រគល់ជូននិយោជកត្រឹមតែសំបុត្រពេទ្យប៉ុណ្ណោះ បើទោះបីជាគាត់បានដឹងពីនីតិវិធីនៃការសុំច្បាប់ឈប់សម្រាកដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនក៏ដោយ។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងរបស់ភាគីនិយោជកទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត វង់ ថាវី មិនបានអនុវត្តតាមនីតិវិធីសុំច្បាប់ដែលមានចែងក្នុងប្រការ ១០.១ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ជូនកម្មករនិយោជិត វង់ ថាវី នៅពេលដែលគាត់ឈប់សម្រាកដោយមិនបានសុំការអនុញ្ញាតត្រឹមត្រូវនោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត វង់ ថាវី នៅពេលដែលគាត់ឈប់សម្រាកដោយមិនបានសុំការអនុញ្ញាតត្រឹមត្រូវ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបញ្ជាក់ឈ្មោះសហជីព ដែលនិយោជកបានកាត់ប្រាក់ភាគទានជូន នៅលើបង្កាន់ដៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត វង់ ថាវី នៅពេលដែលគាត់ឈប់សម្រាកដោយមិនបានសុំការអនុញ្ញាតត្រឹមត្រូវ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**
**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**
ឈ្មោះ ៖ **អ៊ឹម សុទ្ធី**
ហត្ថលេខា ៖ ---------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទូន ស៊ីផាន់**

ហត្ថលេខា ៖---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ---------------------------------